១-ត្រូវមាន ឬមានភស្តុតាងបញ្ជាក់ថានឹងមានឧបករណ៍និងប្រព័ន្ធព័ត៌មានវិទ្យាដែលអាចភ្ជាប់បណ្តាញជាមួយប្រព័ន្ធព័ត៌មានវិទ្យារបស់ **ផ.ម.ក.**។

២-ត្រូវមាន ឬមានភស្តុតាងបញ្ជាក់ថានឹងមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាដែលតភ្ជាប់បណ្តាញជាមួយប្រព័ន្ធព័ត៌មានវិទ្យារបស់ **ផ.ម.ក.** ស្របតាមលក្ខខណ្ឌតម្រូវដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ៥.- ថ្លៃការអនុញ្ញាតសម្រាប់ការចូលជាសមាជិក ឬអ្នកចូលរួម**

បុគ្គលដាក់ពាក្យស្នើសុំចូលជាសមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃការអនុញ្ញាតដូចខាងក្រោម :

១-សមាជិកត្រូវបង់ថ្លៃការអនុញ្ញាតចូលជាសមាជិកសរុបចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល សម្រាប់សមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

២-អ្នកចូលរួមត្រូវបង់ថ្លៃការអនុញ្ញាតជា ÷

ក-ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល។

ខ-ភ្នាក់ងារបញ្ជិកាមូលបត្រចំនួន ២.០០០.០០០ (ពីរលាន) រៀល។

គ-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រចំនួន ២.០០០.០០០ (ពីរលាន) រៀល។

ឃ-ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបានលើកលែងការបង់ថ្លៃសម្រាប់ការអនុញ្ញាតធ្វើជាអ្នកចូលរួម។

## ជំពូកទី ៣
## ការដកហូតសមាជិកភាព ឬការចូលរួម

### ប្រការ ៦.- ការដកសមាជិកភាព ឬការចូលរួម ដោយស្ម័គ្រចិត្ត

ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមណាមួយមានបំណងស្នើសុំដកសមាជិកភាព ឬការចូលរួមរបស់ខ្លួន បុគ្គលនោះត្រូវដាក់សំណើសុំដកសមាជិកភាព ឬការចូលរួមទៅ **ផ.ម.ក.**។

ការដកសមាជិកភាព ឬការចូលរួម ព្រមទាំងកាលបរិច្ឆេទសុពលភាពនៃការដកសមាជិកភាពឬការចូលរួមត្រូវសម្រេចដោយ **ផ.ម.ក.**។

### ប្រការ ៧.- ការដកហូតសមាជិកភាព ឬការចូលរួម

**ផ.ម.ក.** នឹងចាត់នីតិវិធីដកសមាជិកភាព ឬបញ្ឈប់ការចូលរួមពីសមាជិក ឬអ្នកចូលរួម ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមនោះស្ថិតក្នុងស្ថានភាពដូចខាងក្រោម÷

១-ការដកហូតអាជ្ញាបណ្ណ ឬការទទួលស្គាល់ដើម្បីធ្វើអាជីវកម្មមូលបត្រ ឬការផ្ទេរអាជីវកម្ម ឬការបិទអាជីវកម្ម។

២-ការរំលាយក្រុមហ៊ុន។

៣-ការដកហូតសមាជិកភាព ឬការបញ្ឈប់ការចូលរួម។

### ប្រការ ៨.- ការផ្ទេរសមាជិកភាព ឬការចូលរួម

បុគ្គលដែលមានបំណងផ្ទេរសមាជិកភាព ឬការចូលរួមដែលជាលទ្ធផលនៃការផ្ទេរអាជីវកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នាជាដើម ត្រូវដាក់ពាក្យស្នើសុំផ្ទេរសមាជិកភាព ឬការចូលរួមទៅ **ផ.ម.ក.**។

សមាជិកភាព ឬការចូលរួមដែលត្រូវបានផ្ទេរស្របតាមកថាខណ្ឌទី ១ អាចត្រូវបានប្រគល់ឱ្យក្រុមហ៊ុនដែលនៅបន្តដំណើរការ ឬក្រុមហ៊ុនដែលត្រូវបានបង្កើតថ្មី ដោយមានការយល់ព្រមពី **ផ.ម.ក.**។

ក្នុងករណីដែលមានការផ្ទេរសមាជិកភាពស្របតាមកថាខណ្ឌទី ១ រាល់ការជួញដូរមូលបត្រទាំងឡាយដែលមិនបានទូទាត់របស់សមាជិកនោះ ត្រូវចាត់ទុកថាជាការជួញដូរដោយក្រុមហ៊ុនដែលនៅបន្តដំណើរការ ឬក្រុមហ៊ុនដែលត្រូវបានបង្កើតថ្មី។

### ប្រការ ៩.- ការបញ្ចប់ និងការផ្តល់សមាជិកភាព ឬការចូលរួមជាថ្មី

សមាជិកភាព ឬការចូលរួមត្រូវមានសុពលភាពរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃដែលសមាជិក

ភាពឬការចូលរួមត្រូវបានសម្រេចដោយ ជ.ម.ក.។ សមាជិកភាព ឬការចូលរួមដែលត្រូវបានបន្តថ្មីនឹងមានសុពលភាពរយៈពេល ០៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលសុពលភាពចាស់ផុតកំណត់។

សមាជិក ឬអ្នកចូលរួមដែលមានបំណងបន្តសមាជិកភាពរបស់ខ្លួន ត្រូវបំពេញបែបបទដើម្បីបន្តសុពលភាពយ៉ាងហោចណាស់ ៤៥ (សែសិបប្រាំ) ថ្ងៃ មុនថ្ងៃដែលសុពលភាពផុតកំណត់។

លក្ខខណ្ឌតម្រូវនានានៃការស្នើសុំបន្តសមាជិកភាព ឬការចូលរួម ត្រូវដូចគ្នានឹងលក្ខខណ្ឌតម្រូវនៃការស្នើសុំសមាជិកភាព ឬការចូលរួមលើកដំបូង ដែលមានចែងក្នុងប្រការ ៣ ខាងលើ។

ការស្នើសុំបន្តសមាជិកភាព ឬការចូលរួមស្របតាមកថាខណ្ឌទី ២ និងទី ៣ ខាងលើ ត្រូវសម្រេចដោយ ជ.ម.ក. និងត្រូវបង់ថ្លៃការអនុញ្ញាតចូលជាសមាជិកឬអ្នកចូលរួម ស្របតាមប្រការ ៥ នៃវិធាននេះ។

សេចក្តីសម្រេចផ្តល់ការអនុញ្ញាតបន្តធ្វើជាសមាជិក ឬជាអ្នកចូលរួម ត្រូវផ្តល់ដោយ ជ.ម.ក. បន្ទាប់ពីសមាជិក ឬអ្នកចូលរួម បានបំពេញបែបបទបន្តត្រឹមត្រូវ និងបានបង់ថ្លៃសេវាផ្សេងៗដូចមានចែងក្នុងវិធាននេះ។

**ប្រការ ១០.- ការព្យួរការជួញដូរ និងការទូទាត់លើការជួញដូរដែលមិនទាន់ទូទាត់**

ចំពោះបុគ្គលដែលបានដាក់ពាក្យស្នើសុំដកសមាជិកភាព ឬការចូលរួមរបស់ខ្លួនស្របតាមប្រការ ៦ ខាងលើ ឬក៏សមាជិកភាព ឬការចូលរួមរបស់ខ្លួនត្រូវបានដកហូតស្របតាមប្រការ ៧ ខាងលើ សមាជិក ឬអ្នកចូលរួមនោះ ត្រូវបានព្យួរការប្រើប្រាស់សេវារបស់ ជ.ម.ក. ចាប់ពីថ្ងៃដែលការដកហូតសមាជិកភាពឬការចូលរួមត្រូវបានសម្រេចជាផ្លូវការដោយ ជ.ម.ក.។

## ជំពូកទី ៤
## សិទ្ធិ និងភារកិច្ចរបស់សមាជិកនិងអ្នកចូលរួម

**ប្រការ ១១.- សិទ្ធិរបស់សមាជិក និងអ្នកចូលរួម**

សមាជិកនិងអ្នកចូលរួមមានសិទ្ធិប្រើប្រាស់សេវារបស់ ជ.ម.ក. សម្រាប់ការជួញដូរមូលបត្រ ការជាត់ទាត់និងទូទាត់មូលបត្រ និងការរក្សាទុកមូលបត្រ ស្របតាមការសម្រេចរបស់ ជ.ម.ក. ពាក់ព័ន្ធនឹងការបែងចែករវាងសមាជិកនិងអ្នកចូលរួម និងពាក់ព័ន្ធនឹងវិធានការវិន័យដូចមានចែងក្នុងវិធានរបស់ ជ.ម.ក. ដែលទទួលបានការអនុម័តដោយ គ.ម.ក.។

**ប្រការ ១២.- ការបង់ថ្លៃសេវា**

សមាជិក ឬអ្នកចូលរួម ដែលទទួលបានការអនុញ្ញាតពី ជ.ម.ក. ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំដូចខាងក្រោម :

១-សមាជិកត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៥០.០០០.០០០ (ហាសិបលាន) រៀល ដល់ ផ.ម.ក នៅមុនដំណាច់ឆ្នាំនីមួយៗ។

២-សម្រាប់អ្នកចូលរួមជា :

ក-ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ១០.០០០.០០០ (ដប់លាន) រៀល។

ខ-ភ្នាក់ងារបញ្ជិកាមូលបត្រត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ២.០០០.០០០ (ពីរលាន) រៀល។

គ-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤.០០០.០០០(បួនលាន) រៀល។

ឃ-អ្នកចូលរួមជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបានលើកលែងការបង់ថ្លៃសេវាប្រចាំឆ្នាំ។

សម្រាប់ឆ្នាំសារពើពន្ធដំបូងនៃការអនុញ្ញាតដំបូង សមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំនៅពេលដែលទទួលបានការអនុញ្ញាតដោយគណនាផ្អែកលើចំនួនថ្ងៃដែលនៅសល់ រហូតដល់ចុងឆ្នាំសារ-ពើពន្ធ។ សម្រាប់ឆ្នាំសារពើពន្ធបន្តបន្ទាប់ សមាជិកឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំនេះ ឱ្យបានមុនថ្ងៃទី ១៥ ខែ ធ្នូ នៃឆ្នាំសារពើពន្ធចាស់។

**ប្រការ ១៣.- ការទូទាត់លើការជួញដូរមូលបត្រ**

សមាជិក ត្រូវមានកាតព្វកិច្ចទូទាត់លើរាល់ប្រតិបត្តិការមូលបត្រដែលខ្លួនបានអនុវត្ត នៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក.។

សមាជិក ត្រូវបានហាមឃាត់មិនឱ្យធ្វើការអនុញ្ញាតឱ្យភាគីទី ៣ ធ្វើការទូទាត់លើប្រតិបត្តិការមូល-បត្រក្នុងនាមរបស់ខ្លួនឡើយ។

**ប្រការ ១៤.- ការអនុវត្តតាមច្បាប់ និងបទបញ្ញត្តិនានា**

សមាជិក និងអ្នកចូលរួមទាំងអស់ត្រូវអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិស្ដីពីអាជីវកម្មមូលបត្រ ព្រមទាំងវិធានរបស់ ផ.ម.ក. ដែលរួមទាំងវិធានប្រតិបត្តិការទីផ្សារមូលបត្រ វិធានប្រតិបត្តិការជាត់ទាត់និងទូទាត់មូលបត្រ វិធានប្រតិបត្តិការរក្សាទុកមូលបត្រ ព្រមទាំងចំណាត់ការ ឬវិធានការផ្នែកវិន័យដែលត្រូវបានអនុវត្តស្របតាមច្បាប់និងបទប្បញ្ញត្តិនានា។

**ប្រការ ១៥.- កិច្ចព្រមព្រៀងផ្ដល់សេវា**

នៅពេលបើកគណនី សមាជិកនិងអ្នកចូលរួម ត្រូវចុះកិច្ចព្រមព្រៀងផ្ដល់សេវាជាមួយ ផ.ម.ក. តាមគំរូដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

សមាជិក និងអ្នកចូលរួមត្រូវផ្តល់ជូន **ផ.ម.ក.** នូវគំរូនៃកិច្ចព្រមព្រៀងសេវារវាងសមាជិកឬអ្នកចូលរួម និងអតិថិជនរបស់ខ្លួន ដែលបានបង្កើតឡើងស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធរបស់ **គ.ម.ក.**។

## ជំពូកទី ៥
## ការត្រួតពិនិត្យសមាជិក និងអ្នកចូលរួម

### ប្រការ ១៦.- របាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ

សមាជិកត្រូវផ្តល់ជូន **ផ.ម.ក.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច ព្រមទាំងព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។ អ្នកចូលរួមត្រូវផ្តល់ជូន **ផ.ម.ក.** នូវរបាយការណ៍ និងព័ត៌មានដែលកំណត់ដោយ **គ.ម.ក.**។

### ប្រការ ១៧.- សំណើសុំផ្តល់ព័ត៌មាន

**ផ.ម.ក.** អាចស្នើឱ្យសមាជិក និងអ្នកចូលរួមផ្តល់នូវព័ត៌មានពាក់ព័ន្ធក្នុងករណីដូចខាងក្រោម :

១-ករណីដែលមានភាពចាំបាច់ក្នុងការបញ្ជាក់ឱ្យដឹងច្បាស់ថា សមាជិក និងអ្នកចូលរួមពិតជាបានអនុវត្តត្រឹមត្រូវតាមការណែនាំនៃវិធាននេះ ឬតាមកាតព្វកិច្ចរបស់ខ្លួន។

២-ករណីដែលមានភាពចាំបាច់ សម្រាប់ការគ្រប់គ្រងដំណើរការទីផ្សារប្រកបដោយរបៀបរៀបរយ។

### ប្រការ ១៨.- វិធានការវិន័យចំពោះសមាជិក និងអ្នកចូលរួម

ចំពោះសមាជិកនិងអ្នកចូលរួម ដែលមិនអនុវត្តតាមវិធានទាំងឡាយរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា **ផ.ម.ក.** អាចចាត់វិធានការវិន័យក្នុងចំណោមវិធានការដូចខាងក្រោម :

១-ការព្រមាន។

២-ការព្យួរសមាជិកភាព ឬការចូលរួមទាំងស្រុង ឬផ្នែកណាមួយ ដែលអាចមានក្នុងរយៈពេលកំណត់ណាមួយ។

៣-ការបញ្ឈប់ពីសមាជិកភាព ឬពីការចូលរួមនៃ **ផ.ម.ក.**។

### ប្រការ ១៩.- ការជូនដំណឹងអំពីការចាត់វិធានការ

នៅពេលដែលវិធានការដូចជាការបញ្ឈប់ ឬការព្យួរសមាជិកភាព ឬការចូលរួមទាំងស្រុងឬមួយផ្នែក ឬការព្យួរសិទ្ធិជួញដូរទាំងស្រុង ឬមួយផ្នែក ត្រូវបានអនុវត្តចំពោះសមាជិក ឬអ្នកចូលរួមណាមួយ មុន[illegible]

ដែលវិធានការដែលបានអនុវត្តត្រូវបានបញ្ចប់ **ផ.ម.ក.** ត្រូវផ្ដល់ដំណឹងអំពីករណីនេះភ្លាមដល់សមាជិក និងអ្នកចូលរួមដទៃទៀត។

## **ជំពូកទី ៦**

## **អន្តរប្បញ្ញត្តិ**

**ប្រការ ២០.- សុពលភាពនៃសមាជិកភាព ឬការចូលរួមលើកទីមួយ**

សម្រាប់ការចូលជាសមាជិក ឬជាអ្នកចូលរួមលើកទីមួយ សមាជិកភាព ឬការចូលរួមត្រូវមានសុពលភាពស្មើនឹងសុពលភាពនៅមាននៃអាជ្ញាបណ្ណ ឬការទទួលស្គាល់ ដែលចេញដោយ **គ.ម.ក.** ហើយថ្លៃនៃការអនុញ្ញាតសម្រាប់ការចូលជាសមាជិក ឬអ្នកចូលរួមនេះត្រូវគិតជាប្រូរ៉ាតា (Pro Rata)។

*****

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:......០០៤/១១......គ.ម.ក ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិករវក្សាទុកមូលបត្រ

- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញសំណើសុំការពិនិត្យ និងអនុម័ត លើវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១១

**គាត ឈន់**

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ ..០០៨/១១ គ.ម.ក. ប្រ.ក.
ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១

# វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់អំពីគោលការណ៍នានាដែលចាំបាច់សម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងវិធាននេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

-**បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដំបូង** សំដៅដល់បុគ្គលដែលមានបំណងធ្វើសំណើចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ដែលមិនធ្លាប់បានចុះបញ្ជីលក់នៅ **ផ.ម.ក.**។

-**បុគ្គលចុះបញ្ជីលក់មូលបត្រ** សំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយបានចុះបញ្ជីលក់មូលបត្រនោះនៅ **ផ.ម.ក.**។

-**ក្រុមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ** សំដៅដល់ភាគហ៊ុនិក និងបុគ្គលពាក់ព័ន្ធពិសេសនៃក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេរបស់ក្រុមហ៊ុន។ ក្នុងករណីនេះ ភាគហ៊ុនដែលកាន់កាប់ក្នុងគោលបំណងវិនិយោគជាកញ្ចប់ដោយវិនិយោគិនស្ថាប័ន ត្រូវបានដកចេញពីការគណនាចំនួនភាគហ៊ុនដែលកាន់កាប់ដោយក្រុមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ។

## ជំពូកទី ២
## ការចុះបញ្ជីលក់មូលបត្រ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**ប្រការ ៣.- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ហិរញ្ញវត្ថុដែលត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវរៀបចំឡើង និងធ្វើសវនកម្ម ដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ព្រមទាំងបទប្បញ្ញត្តិជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានហិរញ្ញវត្ថុលម្អិតដែលតម្រូវនៅក្នុងវិធាននេះ ត្រូវរៀបចំឡើងដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ៤.- ការមិនសងត្រលប់ទៅវិញនូវឯកសារពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជី និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ**

រាល់ឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំដើម្បីពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ ដែលតម្រូវដោយវិធាននេះ មិនត្រូវប្រគល់ជូនបុគ្គលស្នើសុំវិញនោះទេ ទោះបីពាក្យស្នើសុំនោះត្រូវបានបដិសេធ ឬត្រូវបានដកទៅវិញក៏ដោយ។

### ផ្នែកទី ២
### លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

**ប្រការ ៥.- ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ**

បុគ្គលដែលមានបំណងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ **ជ.ម.ក.** ត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

**ប្រការ ៦.- ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ**

បុគ្គលដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវភ្ជាប់មកជាមួយនូវឯកសារមក **ជ.ម.ក.** ដូចខាងក្រោម ៖

១-ព័ត៌មានទូទៅ ៖

ក-ឈ្មោះរបស់ក្រុមហ៊ុនជាភាសាខ្មែរ និងអក្សរឡាតាំង។

ខ- អាសយដ្ឋានក្រុមហ៊ុន។

គ- កាលបរិច្ឆេទបង្កើតក្រុមហ៊ុន។

ឃ- កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន។

ង- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

ច- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២- ព័ត៌មានអំពីបុគ្គលតំណាងក្រុមហ៊ុន : អត្តសញ្ញាណបុគ្គលតំណាងក្រុមហ៊ុន។

៣- ព័ត៌មានអំពីភាគហ៊ុនិក : អត្តសញ្ញាណភាគហ៊ុនិក។

៤- ព័ត៌មានអំពីលក្ខខណ្ឌបរិមាណ :

ក- មូលធនភាគហ៊ុនិកសរុបគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

ខ- ប្រាក់ចំណេញសុទ្ធ ០៣ (បី) ឆ្នាំចុងក្រោយ។

គ- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ០៣ (បី) ឆ្នាំចុងក្រោយ។

ឃ- ប្រភេទមូលបត្រដែលត្រូវបោះផ្សាយ និងជួញដូរនៅ **ផ.ម.ក.**។

**ប្រការ ៧.- ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជី**

**ផ.ម.ក.** ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រទៅបុគ្គលដាក់ពាក្យស្នើសុំក្នុងរយៈពេល យ៉ាងយូរបំផុតត្រឹម ០១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំ។

ករណី **ផ.ម.ក.** បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្ររបស់បុគ្គលដាក់ពាក្យស្នើសុំ **ផ.ម.ក.** ត្រូវពន្យល់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលដាក់ពាក្យស្នើសុំអាចស្នើសុំការបំភ្លឺពី **ផ.ម.ក.**។ បុគ្គលដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក **គ.ម.ក.** ចំពោះការបដិសេធនោះ ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី ៣

## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

**ប្រការ ៨.- នីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ**

បុគ្គលដែលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ **ផ.ម.ក.** ត្រូវបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ **ផ.ម.ក.** ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមូលបត្រត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម។

**ប្រការ ៩.- ឯកសារដែលត្រូវផ្តល់ជូន ផ.ម.ក.**

ក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រផ្លូវការនៅ ផ.ម.ក. បុគ្គលដែលទទួលបានការបញ្ជាក់

ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវផ្តល់ជូន ផ.ម.ក. នូវឯកសារដូចខាងក្រោម÷

១-ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ គ.ម.ក.។

២-ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ។

៣-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

៤-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់។

៥-របាយការណ៍បែងចែកមូលបត្រ។

៦-លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

**ប្រការ ១០.- ការចុះបញ្ជីលក់មូលបត្រជាផ្លូវការ**

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញដូចមានចែងក្នុងប្រការ ៩ នៃវិធាននេះ ផ.ម.ក. ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ ១១.- កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ**

មុននឹងត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រតាមគំរូដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី ១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

**ប្រការ ១២.- លក្ខខណ្ឌតម្រូវជាតួលេខ**

បុគ្គលដែលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម លើកលែងតែមានការកំណត់លក្ខខណ្ឌផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. :

១-ចំនួនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% (មួយភាគរយ) : ចំនួនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% (មួយភាគរយ) ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

២-ចំនួនភាគហ៊ុនរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង១% (មួយភាគរយ) : ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតតិចជាង ១% (មួយភាគរយ) ត្រូវមានចំនួនសរុបចាប់ពី ២០០.០០០ (ពីរសែន) ភាគហ៊ុនឡើងទៅ

១៥% (ដប់ប្រាំភាគរយ) នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប ដោយយកចំនួនណាមួយដែលធំជាងគេ។

**ប្រការ ១៣.- លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ**

បុគ្គលដែលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ **ផ.ម.ក.** ដោយត្រូវបំពេញលក្ខខណ្ឌតម្រូវមិនមែនជាតួលេខដូចខាងក្រោម :

១-មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយរហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

២-មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

## ជំពូកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

**ប្រការ ១៤.- លក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ**

**ផ.ម.ក** ត្រូវដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការនូវមូលបត្ររបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រក្នុងករណីណាមួយដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** :

១-ករណីដែលក្រុមហ៊ុនមិនបានដាក់របាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធចុងក្រោយក្នុងអំឡុងពេល ០៣ (បី) ខែ បន្ទាប់ពីកាលវសានដែលកំណត់ដោយ **គ.ម.ក.**។

២-ករណីដែលយោបល់របស់សវនករនៅក្នុងរបាយការណ៍សវនកម្មរបស់ក្រុមហ៊ុន មានយោបល់ជំទាស់ ឬបដិសេធ សម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំ។

៣-ករណីដែលរបាយការណ៍ប្រចាំឆ្នាំបានបង្ហាញថា មូលធនភាគហ៊ុនិករបស់ក្រុមហ៊ុនបានថយចុះក្នុងរយៈពេល ០២ (ពីរ) ឆ្នាំជាប់គ្នា ច្រើនជាង ៥០% (ហាសិបភាគរយ)។

៤-ករណីដែលមានការបំពានលើកាតព្វកិច្ចផ្តល់ព័ត៌មានជាញឹកញាប់។

៥-ករណីដែលក្រុមហ៊ុនមិនអាចទូទាត់ជាស្ថាពរលើផលបត្រពាណិជ្ជកម្ម ឬមូលប្បទានបត្រដែលខ្លួនបានចេញ ឬប្រតិបត្តិការរបស់ខ្លួនជាមួយធនាគារពាណិជ្ជត្រូវបានព្យួរ។

៦-ករណីដែលក្រុមហ៊ុនស្ថិតក្រោមករណីណាមួយ នៃមូលហេតុរំលាយក្រុមហ៊ុនយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-ករណីដែលក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបានដាក់កំហិតក្នុងការផ្ទេរកម្មសិទ្ធិភាគហ៊ុន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តនោះទេ ចំពោះករណីដែលការដាក់កំហិតត្រូវបានចាត់ទុកថាមិន

ប៉ះពាល់ដល់ការជួញដូរនៅលើទីផ្សារ ពីព្រោះការដាក់កំហិតនេះត្រូវធ្វើឡើងដោយច្បាប់ផ្សេងទៀតដែលមិនពាក់ព័ន្ធដល់វិស័យមូលបត្រ។

**ប្រការ ១៥.- ការជូនដំណឹងជាសាធារណៈ និងការអនុញ្ញាតលើការជួញដូរលើមូលបត្រដែលដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ**

នៅពេលដកចេញពីបញ្ជីនូវមូលបត្រចុះបញ្ជីលក់មូលបត្រជាផ្លូវការណាមួយ ផ.ម.ក.ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីការដកពីបញ្ជីនូវមូលបត្រដែលពាក់ព័ន្ធ។

ករណីដកចេញពីបញ្ជីនូវមូលបត្រណាមួយ ផ.ម.ក. អាចអនុញ្ញាតឱ្យមានការជួញដូរបន្តលើមូលបត្រនោះ សម្រាប់រយៈពេល ១០ (ដប់) ថ្ងៃ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

## ជំពូកទី ៤
## ការគ្រប់គ្រងលើមូលបត្រដែលបានចុះបញ្ជីលក់

**ប្រការ ១៦.- កាតព្វកិច្ច និងនីតិវិធីផ្តល់ព័ត៌មាន**

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវដាក់ជូន ផ.ម.ក.ឱ្យទាន់ពេលវេលានូវឯកសារផ្តល់ព័ត៌មាន និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានរបស់ខ្លួន ស្របតាមការកំណត់របស់គ.ម.ក.។

**ប្រការ ១៧.- កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុន**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រដំបូង ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យា ដែលក្នុងនោះក្រុមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនភាគច្រើនលើសលប់ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ០១ (មួយ) ឆ្នាំ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥% (ដប់ប្រាំភាគរយ) ឡើងទៅ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនដែលខ្លួនកាន់កាប់យ៉ាងហោចណាស់ សម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីចុះបញ្ជីលក់មូលបត្រដំបូង។

**ប្រការ ១៨.- ការព្យួរការជួញដូរ និងការចាប់ផ្តើមជួញដូរជាថ្មី**

ផ.ម.ក អាចព្យួរការជួញដូរមូលបត្រក្នុងករណីណាមួយដូចខាងក្រោម :

១-ករណីភាគហ៊ុនចុះបញ្ជីលក់មួយផ្នែក ឬទាំងស្រុង មានការក្លែងបន្លំ។

២-ករណីដែលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការណាមួយនៃប្រការ ១៤ ដែលវិធានការនៃការដកចេញពីបញ្ជីលក់មូលបត្រមិនទាន់បានអនុវត្ត។

៣-ករណីមានការបំបែក ឬការបង្រួមមូលបត្រកម្មសិទ្ធិ ឬតាមសំណើរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤-ករណីមានការសម្រេចពីអគ្គនាយកនៃ **គ.ម.ក.**។

ការព្យួរការជួញដូរមូលបត្រ ស្របតាមកថាខណ្ឌទី ១ ត្រូវបានអនុវត្តរហូតដល់មូលហេតុនៃការព្យួរការជួញដូរត្រូវបានដោះស្រាយរួច លើកលែងតែមានការសម្រេចបន្ថែមពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១៩.- ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម**

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ដែលមានបំណងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែមត្រូវអនុវត្តនីតិវិធីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិដូចមានចែងក្នុងវិធាននេះ។

**ប្រការ ២០.- ពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ**

ករណីមានការកែប្រែឈ្មោះក្រុមហ៊ុន តម្លៃចារឹករបស់មូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ ឬចំនួនមូលបត្រកម្មសិទ្ធិបោះផ្សាយ បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវបំពេញនីតិវិធីកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ **ផ.ម.ក.**។

**ប្រការ ២១.- ការជូនដំណឹងអំពីការក្លែងបន្លំផ្ទេរមូលបត្រ**

ករណីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** អំពីករណីមានការក្លែងបន្លំក្នុងការផ្ទេរមូលបត្រកម្មសិទ្ធិ បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវជូនដំណឹងភ្លាមមក **ផ.ម.ក.**។ ការជូនដំណឹងមក **ផ.ម.ក.** នេះ អាចធ្វើឡើងតាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

## ជំពូកទី ៥

## ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

**ប្រការ ២២.- ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ និងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ**

បុគ្គលស្នើសុំការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាចំនួន ៤.០០០.០០០(បួនលាន) រៀលជូន **ផ.ម.ក.**។

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាសម្រាប់ការចុះបញ្ជីមូលបត្រជូន **ផ.ម.ក.** ស្មើនឹង ០,១០% (សូន្យក្បៀសដប់ភាគរយ) នៃចំនួនទឹកប្រាក់មូលធនូបនីយកម្មទីផ្សារសរុប (Market Capitalization) ដោយគិតតាមថ្លៃបោះផ្សាយលក់លើកដំបូង។

**ប្រការ ២៣.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ**

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំទៅតាមមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយដូចខាងក្រោម :

១-ប្រសិនបើមូលធនូបនីយកម្មទីផ្សារ តិចជាងឬស្មើនឹង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល ត្រូវបង់សេវា ៣.០០០.០០០(បីលាន) រៀល។

២-ប្រសិនបើមូលធនូបនីយកម្មទីផ្សារច្រើនជាង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល និងតិចជាងឬស្មើនឹង ៤០.០០០.០០០.០០០(សែសិបពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម :

ក-មូលធនូបនីយកម្មទីផ្សារស្មើនឹង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល ត្រូវបង់សេវា ៣.០០០.០០០(បីលាន) រៀល។

ខ-មូលធនូបនីយកម្មទីផ្សារនៅសល់ត្រូវបង់ ០,០២%(សូន្យក្បៀសពីរភាគរយ)។

៣- មូលធនូបនីយកម្មទីផ្សារច្រើនជាង ៤០.០០០.០០០.០០០ (សែសិបពាន់លាន)រៀល និងតិចជាងឬស្មើនឹង ២០០.០០០.០០០.០០០(ពីររយពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម :

ក-មូលធនូបនីយកម្មទីផ្សារស្មើនឹង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល ត្រូវបង់សេវា ៣.០០០.០០០(បីលាន) រៀល។

ខ-មូលធនូបនីយកម្មទីផ្សារស្មើនឹង ២៨.០០០.០០០.០០០ (ម្ភៃប្រាំបីពាន់លាន)រៀល ត្រូវបង់សេវា ៥.៦០០.០០០(ប្រាំលាន និងប្រាំមួយសែន) រៀល។

គ-មូលធនូបនីយកម្មទីផ្សារ នៅសល់ត្រូវបង់សេវា ០,០១៥%(សូន្យក្បៀសមួយភាគរយកន្លះ)។

៤-មូលធនូបនីយកម្មទីផ្សារច្រើនជាង ២០០.០០០.០០០.០០០(ពីររយពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម ÷

ក- មូលធនូបនីយកម្មទីផ្សារ ស្មើនឹង១២.០០០.០០០.០០០(ដប់ពីរពាន់លាន) រៀល ត្រូវបង់សេវា ៣.០០០.០០០(បីលាន) រៀល។

ខ- មូលធនូបនីយកម្មទីផ្សារ ស្មើនឹង ២៨.០០០.០០០.០០០ (ម្ភៃប្រាំបីពាន់លាន) រៀល ត្រូវបង់សេវា ៥.៦០០.០០០(ប្រាំលាន និងប្រាំមួយសែន) រៀល។

គ- មូលធនូបនីយកម្មទីផ្សារស្មើនឹង ១៦០.០០០.០០០.០០០ (មួយរយហុកសិបពាន់លាន) រៀល ត្រូវបង់សេវា ០,០១៥ % (សូន្យក្បៀសមួយភាគរយកន្លះ)ឬស្មើនឹង ២៤.០០០.០០០ (ម្ភៃបួនពាន់លាន) រៀល។

ឃ-មូលធនូបនីយកម្មទីផ្សារ នៅសល់ត្រូវបង់សេវា ០,០០៥%។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**ប្រការ ២៤.- អញ្ញត្រកម្ម**

ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំដំបូងនៃការអនុវត្តវិធាននេះ តាមការជាក់ស្តែង **ផ.ម.ក.** អាចស្នើសុំមកអគ្គនាយកនៃ **គ.ម.ក.** ក្នុងការបន្ធូរបន្ថយលើលក្ខខណ្ឌតម្រូវពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការចុះបញ្ជីលក់មូលបត្រជាផ្លូវការដល់បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ។

*****

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៦០៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **ជី.ធី.អេហ្វ. វើលវ៉ាយដ៍ (ខេមបូឌា)**<br>**G.T.F. WORLDWIDE (CAMBODIA) Co., Ltd.** |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : | Co. ១៥២៤E/២០១០ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០ |
| មានទ្រង់ទ្រាយជា | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ២- អភិបាលក្រុមហ៊ុន | : | លោក VERAYUTH SUTTHIPHANA ប្រធានក្រុមប្រឹក្សាភិបាល<br>លោកស្រី LIM LI LING អភិបាល |
| ៣- ដើមទុនក្រុមហ៊ុន | : | ២០.០០០.០០០ រៀល |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | លេខ ១១០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : | -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ និហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ<br>-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ<br>-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ<br>-បើកសាលារៀន<br>-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវាកេការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស<br>-សេវាផ្នែកពត៌មានវិទ្យា<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីដេអូ CD<br>-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាចែកចាយទំនិញ<br>-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន<br>-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់ -សិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ<br>-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត<br>-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ<br>-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ ... |

៦- ចិរវេលា : ៩៩ ឆ្នាំ

រាលដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សសរ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៤០៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ី.អេច.អិម ខនស្ត្រាក់សិន**
C.H.M CONSTRUCTION Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៥២៥E/២០១០ ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី LIU NAN ប្រធានក្រុមប្រឹក្សាភិបាល
លោក **សាន យន់ឡុង** "គតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ១០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ០៦ ផ្លូវលេខ ៦០២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម: ទិញ លក់ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញ - នាំចូលឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះ និងព្យាបាលជម្ងឺ
-បើកសាលារៀន
-សេវាផ្សាយពាណិជ្ជកម្ម
-សេវាផ្នែកពតិមានវិទ្យា
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-ផលិតខ្សែភាពយន្ត វីដេអូ CD
-សេវាបោះពុម្ពផ្សាយ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូនទំនិញ និងថែរក្សាទំនិញ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត-ទីភ្នាក់ងារទេសចរណ៍

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។l

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។l

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាម ប្រសិទ្ធ

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ក.ស.ន - ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ៣១០៤ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា** :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **ពេជ្រ សំណាង ដាវីត ហូលឌីង**
**PICH SAMNANG DAVID HOLDING Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៥១៦KH/២០១០ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកឧកញ៉ា **ពេជ្រ សំណាង** ប្រធានក្រុមប្រឹក្សាភិបាល
លោកជំទាវ **កែវ ស្រី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១ AB ផ្លូវលេខ ២០០៤ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកគំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា និងត្រា**

**ចាម ប្រសិទ្ធ**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
លេខ ៣៧០៩ ពណ.ចបព

ភ្នំពេញថ្ងៃទី០២ ខែសីហា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន CHINA CITY CONSTRUCTION SIXTH ENGINEERING BUREAU GROUP Co.,Ltd (ចិន) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះ តទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ឆាយណា ស៊ីធី ខនស្រ្តាក់សិន ស៊ីកស៍ អេនជីនារីង ប្យូរ៉ូ គ្រុប (ខេមបូឌា)**
CHINA CITY CONSTRUCTION SIXTH ENGINEERING BUREAU GROUP (CAMBODIA ) Co.,Ltd

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៥៥៥ E/២០១០ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក ZHANG JINPENG "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក LIU ERLI "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ៤០.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥៣ ផ្លូវលេខ ៣១៧ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -សាងសង់ ជួសជុល អាគារ ស្ពានថ្នល់ ប្រព័ន្ធធារាសាស្រ្ត ហេដ្ឋារចនាសម្ព័ន្ធ
-ស្ថាបត្យកម្ម សិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ពិសេស សំភារៈបរិក្ខារសំណង់ -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សព្វផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦-ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ម - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៦១០ ពណ.ចបព

ភ្នំពេញថ្ងៃទី ០២ ខែ ៨ ៣ ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- នាមករណ៍របស់ក្រុមហ៊ុន | : | **អ.ភី.អាយ.ស៊ី. អ៊ិនវេសមេន ប្រាយវេត លីមីធីត**<br>**R.P.I.C. INVESTMENT PRIVATE LIMITED** |
| អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : | **Co. ១៥២៧KH/២០១០** ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១០ |
| មានទ្រង់ទ្រាយជា | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| ២- អភិបាលក្រុមហ៊ុន | : | លោក RAVINDER KUMAR |
| ៣- ដើមទុនក្រុមហ៊ុន | : | ២០.០០០.០០០ រៀល |
| ៤- ទីស្នាក់ការក្រុមហ៊ុន | : | លេខ ៩ ផ្លូវលេខ ១៣៦ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ |
| ៥- កម្មវត្ថុអាជីវកម្ម | : | -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ<br>-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ<br>-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ<br>-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង<br>-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ<br>-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ<br>-បើកសាលារៀន<br>-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម<br>-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម<br>-សេវាផ្សាយពាណិជ្ជកម្ម<br>-បោះពុម្ពផ្សាយ<br>-ផលិតខ្សែភាពយន្ត វីដេអូ CD<br>-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ<br>-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន<br>-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់<br>-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត<br>-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ<br>-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។ |

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ ៣៦៧១ ពណ.ចបព**

ភ្នំពេញថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ភីអឹម ឌីវេឡុបមេន**
PM DEVELOPMENT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៥៣២ KH/២០១០ ចុះថ្ងៃទី ២៩ ខែ កក្កដាឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក PARK YOUNG HO ប្រធានក្រុមប្រឹក្សាភិបាល
លោក **សៀ រតនៈ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ៤០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្លូវហាណូយ ភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦-ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ. ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ហត្ថលេខា និងត្រា**

**ក៏ម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

សម ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
Ministry of Commerce
**លេខ ៣៦១២ ពណ.ចបព**

ភ្នំពេញថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

សាខាក្រុមហ៊ុនបរទេសមួយត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុនដើម : PVEP MEKONG PETROLEUM EXPLORATION PRODUCTION OPERATING ONE MEMBER COMPANY LIMITED in short PVEP MEKONG CO., LTD.

នាមករណ៍របស់សាខា : **សាខាក្រុមហ៊ុន ភីវីអ៊ីភី មេគង្គ ភេត្រូលៀម អិចប្លរេសិន ប្រូដាក់សិន អបភើរេធីង វ៉ាន់ មេមប៊ើរ ខមភេនី លីមីធីត ហៅ សាខាក្រុមហ៊ុន ភីវីអ៊ីភី មេគង្គ ខូ អិលធីឌី**
**Branch of PVEP MEKONG PETROLEUM EXPLORATION PRODUCTION OPERATING ONE MEMBER COMPANY LIMITED Known as Branch of PVEP MEKONG CO., LTD.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 00៤២Br/២០១០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១០

២- នាយកសាខាក្រុមហ៊ុន : លោក NGUYEN TRAN PHONG

៣- ទីស្នាក់ការសាខា : លេខ ២០ B ផ្លូវលេខ ២៩៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

៤- កម្មវត្ថុអាជីវកម្ម : -សិក្សាស្រាវជ្រាវ រុករកប្រេងកាត និងឧស្ម័ន។

៥- សញ្ជាតិក្រុមហ៊ុន : វៀតណាម

រាល់ដំណាច់ឆ្នាំនីមួយៗ នាយកសាខាក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់សាខាក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់សាខាពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ. ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ - កាលប្បវត្តិ